**ធម្មទេសនារបស់លោកអភិបាលអូលីវីយេ**
**អភិបូជាបុណ្យសពអូលីហ៊ុយនៅចំការឡៀង**
**ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៨**
*ព្រះជាម្ចាស់ចង់ឲ្យយើងទទួលជីវិតអស់កល្បជានិច្ច*

បងប្អូនជាទីស្រឡាញ់!

យើងជួបជុំគ្នា ដើម្បីជូនដំណើរចុងក្រោយរបស់ អូលីហ៊ុយ ជាពេលវេលាមួយដើម្បីអធិដ្ឋានទូលអង្វរព្រះជាម្ចាស់ឲ្យព្រះអង្គប្រទានសេចក្ដីសុខសាន្ត ឲ្យវិញ្ញាណខ័ន្ធរបស់អូលីហ៊ុយ និងសូមឲ្យព្រះអង្គគង់នៅជាមួយយើង។ ថ្ងៃនេះ ជាពេលវេលាមួយដែលយើងមិនចង់មានទេ យប់មិញខ្ញុំនៅកំពង់សោមជាមួយក្រុមលោកឪពុកសុន និងយើងកំពុងនិយាយអំពីយាយរបស់ផុន ខ្ញុំបាននិយាយថាយាយរបស់ផុន ដែលទទួលមរណៈភាពប៉ុន្មានខែមុនគាត់បានទទួលសេចក្ដីសុខ គាត់មានជំងឺពិតមែនប៉ុន្តែយើងបានធ្វើដំណើរជាមួយគាត់យូរខែ នៅពេលគាត់ឈឺយើងបានធ្វើបុណ្យកត្តញ្ញូ មួយខែចុងក្រោយយើងបានសូត្រធម៌ មានព្រះសង្ឃដែលបានមក នៅពេលគាត់ទទួលមរណៈភាពគឺគាត់ទៅដោយសុខសាន្ត។

នៅពេលខ្ញុំនិយាយរឿងនេះហើយ ប្រហែលកន្លះម៉ោងក្រោយមក ផុនបានទូរស័ព្ទមកខ្ញុំថា កូនរបស់គាត់ស្លាប់ទៅហើយ នៅពេលនោះខ្ញុំថានៅពេលយើងជាមនុស្សចាស់យើងមានពេលដើម្បីរៀបចំ នៅពេលយើងមានជំងឺយូរឆ្នាំហើយ យើងមានពេលដើម្បីរៀបចំ។ ប៉ុន្តែសម្រាប់អូលីហ៊ុយ យើងនៅពេលនេះ ឥតមានពេល ដូច្នេះយើងដឹងថាគាត់ទៅដោយមិនដឹងខ្លួន ហើយយើងនៅទីនេះយើងមានតែទឹកភ្នែកដើម្បីណែនាំឲ្យគាត់ធ្វើដំណើរជាមួយព្រះជាម្ចាស់។ ខ្ញុំបានរើសអត្ថបទគម្ពីរនេះ ដោយសារព្រះជាម្ចាស់ស្រឡាញ់កូនក្មេងណាស់ និងព្រះជាម្ចាស់ចង់ឲ្យយើងទាំងអស់គ្នា ដើម្បីទទួលជីវិតអស់កល្បជានិច្ច ឲ្យយើងមានចិត្តគំនិតដូចកូនក្មេង ដែលទន្ទឹងរង់ចាំអ្វីៗទាំងអស់ពីឪពុកម្ដាយ ដើម្បីមានសេចក្ដីសុខ។ អំបាញ់មិញ នៅពេលដែលយើងដាក់សពកូននៅក្នុងមឈូស នៅពេលនោះមានភ្លៀងតែប្រាំនាទី នៅពេលនោះផុនថា នេះជាទឹកភ្នែករបស់អូលីហ៊ុយ ប៉ុន្តែម្យ៉ាងទៀតយើងដឹងថាអូលីហ៊ុយ បានទៅជាទេវទូតមួយដែលចាប់ពីពេលនេះតទៅការពារថែរក្សាយើង និងទឹកភ្លៀងដែលយើងបានឃើញពេលនេះ ប្រហែលជាទឹកព្រះពរដែលអូលីហ៊ុយ ជាទេវទូតមួយចង់ផ្ញើដល់យើងដើម្បីឲ្យ យើងបន្តធ្វើដំណើរក្នុងសេចក្ដីសង្ឃឹម។ យើងដឹងថាព្រះជា

ម្ចាស់បានជ្រើសរើស អូលីហ៊ុយ ធ្វើជាកូនរបស់ព្រះជាម្ចាស់ នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥ នៅយប់បុណ្យព្រះយេស៊ូប្រសូត យើងបានធ្វើពិធីជ្រមុជទឹកឲ្យអូលីហ៊ុយ នៅពេលគាត់មានអាយុតែដប់ថ្ងៃ។ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៨ នៅពេលគាត់មានអាយុតែ២ឆ្នាំ មួយខែ គាត់បានទៅដល់ស្ថានបរមសុខ។ ដូច្នេះនៅពេលនេះ យើងជាក្រុមគ្រួសារតែមួយ ដែលចេះលើកទឹកចិត្តគ្នាទៅវិញទៅមក ដើម្បីណែនាំឲ្យឪពុកម្ដាយ លោកតា លោកយាយ បងប្អូនបានទទួលកំលាំងកាយកំលាំងចិត្តខ្លះៗ ដើម្បីបន្តធ្វើដំណើរ ដោយសារជីវិតរបស់យើងរស់នៅបន្តទៀត។ យើងមានអូលីស៊ីម៉ូ ប្រហែលពេលក្រោយយើងមានកូនក្រោយៗទៀត ដោយដឹងថា អូលីហ៊ុយ ស្ថិតនៅអស់កល្បជានិច្ចជាមួយយើងដោយសារចាប់ពីពេលនេះតទៅ អូលីហ៊ុយ អូលីវីយ៉េ ជាទេវទូតដើម្បីការពារយើង។ អាម៉ែន៕